**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងលើការនាំចូលត្បូងពេជ្រមិនទាន់កែច្នៃ និង ការនាំចេញត្បូងពេជ្រដែលបានកែច្នៃរួច ក្នុងការអនុវត្តន៍គម្រោងចេញវិញ្ញាបនបត្រគីមប៊ែរលី

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦/៩៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញសេចក្តីជូនដំណឹងលេខ ធ៩.០៩.៦០១ សជណ ស្តីពីការបញ្ឈប់ការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុ និងត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ របស់ធនាគារជាតិ នៃកម្ពុជា។
- បានឃើញប្រកាសលេខ ២២៨ MOC / SM 2009 ស្តីពីការគ្រប់គ្រងអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ របស់ក្រសួងពាណិជ្ជកម្ម។
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងជំរុញឲ្យមានការវិនិយោគលើវិស័យត្បូងពេជ្រ និងបង្ការការនាំចូល និងការនាំចេញត្បូងពេជ្រមិនទាន់កែច្នៃ ដែលមានទំនាស់មកព្រះរាជាណាចក្រកម្ពុជា ព្រមទាំងចូលរួមចំណែកអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីវិធាន លក្ខខណ្ឌ និងនីតិវិធីក្នុងការចេញវិញ្ញាបនបត្រសម្រាប់ការប្រកបអាជីវកម្មនាំចូល និងនាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងកែច្នៃរួចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះប្រតិបត្តិការរបស់ពាណិជ្ជករ ដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងការនាំចូល ការនាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងកែច្នៃរួច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខណ្ឌនៃប្រទេសដែលអនុវត្តគម្រោងគីមប័រលីប្រូសេស។

**មាត្រា ៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ ៖

-ត្បូងពេជ្រមានទំនាស់ សំដៅដល់ត្បូងពេជ្រមិនទាន់កែច្នៃ ដែលត្រូវបានប្រើប្រាស់ដោយពួកឧទ្ទាម ឬក្រុមសម្ព័ន្ធមិត្តរបស់ពួកគេ ដើម្បីផ្តល់ហិរញ្ញវត្ថុដល់ជម្លោះនានាសំដៅបំផ្លាញរដ្ឋាភិបាលនៃប្រទេសមួយទៀត។

-គីមប័រលីប្រូសេស សំដៅដល់ដំណើរការនៃការគ្រប់គ្រងមួយដែលមានការចូលរួមពីបណ្តាប្រទេសដែលធ្វើការនាំចូល និងនាំចេញត្បូងពេជ្រដែលមិនមានការពាក់ព័ន្ធនឹងត្បូងពេជ្រមានទំនាស់។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៥.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងផ្តល់ការបញ្ជាក់លើវិញ្ញាបនបត្រសម្រាប់ការនាំចូល ការនាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងកែច្នៃរួច ក្រោមការអនុវត្តន៍គម្រោងគីមប័រលីប្រូសេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៣
## វិធានការគ្រប់គ្រងការនាំចូល និងការនាំចេញ

**មាត្រា ៦.-**

បុគ្គលដែលប្រកបអាជីវកម្មនាំចូល នាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងកែច្នៃរួច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានវិញ្ញាបនបត្រនាំចូល និងនាំចេញ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

លក្ខខណ្ឌ និងនីតិវិធីនៃការចេញវិញ្ញាបនបត្រនាំចូល នាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងកែច្នៃរួច ត្រូវកំណត់ដោយប្រកាសដោយឡែក ឬរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា ៧.-**

បុគ្គលដែលដាក់ពាក្យស្នើសុំវិញ្ញាបនបត្រនាំចូល នាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងកែច្នៃរួច ត្រូវបង់កម្រៃសេវា ។

កម្រៃសេវាវិញ្ញាបនបត្រនាំចូល នាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងកែច្នៃរួច ត្រូវកំណត់ដោយប្រកាសរួម រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា ៨.-**

បុគ្គលដែលធ្វើអាជីវកម្មលើការកែច្នៃត្បូងពេជ្រ និងការនាំចូល នាំចេញ ក្រោមការអនុវត្តន៍គម្រោងគីមប៊ែរលី ត្រូវមកបំពេញបែបបទតាមបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ស្របតាមលក្ខខណ្ឌ និងនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យនេះ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ